# មេរៀនទី ១២៤: ហ្វូងមនុស្សស្វាគមន៍ព្រះយេស៊ូវយាងមកយេរូសាឡិម

## ទំនុកដំកើង ១១៨:១៩-២៩ ម៉ាថាយ ២១:១-១១

**គោលបំណង៖** ជាការល្អក្នុងការសសើរដំកើងព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១១៨:២៦**“*សូមឲ្យព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះយេហូវ៉ាបានប្រកបដោយព្រះពរ។*”

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ជីវិត ការសុគត និងការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូវបានធ្វើឲ្យយើងអាចមានជីវិតអស់កល្បជានិច្ចតាមរយៈទំនាក់ទំនងជាមួយទ្រង់។ ទ្រង់គឺជាហេតុផលសម្រាប់ក្តីសង្ឃឹម និងក្តីសុខរបស់យើង។ សរសើរដំកើងព្រះយេស៊ូវចំពោះអ្វីៗទាំងអស់ដែលទ្រង់មាន! ការសរសើរដំកើងព្រះយេស៊ូវគឺច្រើនជាងការអរព្រះគុណព្រះអង្គ។ វាធ្វើឲ្យយើងផ្តោតលើសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង។ ព្រះយេស៊ូវចង់ឲ្យយើងសរសើរដំកើងទ្រង់ដោយផ្ទាល់ខ្លួន និងជាសាធារណៈ ដើម្បីឲ្យអ្នកឯទៀតឃើញសេចក្តីស្រឡាញ់របស់ព្រះអង្គដែរ។ តើអ្វីខ្លះដែលអ្នកអាចសរសើរដំកើងព្រះយេស៊ូវដោយផ្ទាល់ខ្លួន? សរសើរដំកើងទ្រង់ដោយសរសេរនូវកិច្ចការមួយចំនួនដែលទ្រង់បានធ្វើសម្រាប់អ្នក ហើយអរគុណទ្រង់ និងចែកចាយវាទៅកាន់អ្នកដទៃ ដើម្បីអោយអ្នកនោះទទួលព្រះពរផងដែរ។

**ចំរៀង៖** ១. ហូសាណានៅស្ថានខ្ពស់បំផុត ២. ស្តេចលើស្តេច ៣.ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «ស្តេច ម្ចាស់ក្សត្រី អ្នកបំរើ »

១. ឲ្យកុមារចាប់ដៃគូពីរៗនាក់ (ប្រុសគូជាមួយប្រុស ស្រីគូជាមួយស្រី)

២. នៅពេលដែលគ្រូស្រែកថា “ស្តេច” ដៃគូត្រូវសម្រេចចិត្តឲ្យបានលឿនថា អ្នកណាត្រូវដើរតួជាស្តេច អ្នកណាត្រូវដើរតួជាអ្នកបំរើ។ អ្នកបំរើត្រូវលុតជង្គង់ចុះ ស្តេចត្រូវអង្គុយនៅលើខ្នងរបស់អ្នកបំរើនោះ។

៣. នៅពេលដែលឮពាក្យថា “ម្ចាស់ក្សត្រី” អ្នកបំរើត្រូវលុតជង្គង់ចុះ ម្ចាស់ក្សត្រីត្រូវដាក់ជង្គង់លើខ្នងរបស់អ្នកបំរើនោះ។



៤. នៅពេលដែលឮពាក្យថា “អ្នកបំរើ” ពួកគេត្រូវអៀវគ្នា (នរណាជាអ្នកអៀវក៏បាន។)

៥. ក្រុមដែលមិនធ្វើតាមការណែនាំនឹងចាញ់ល្បែងនេះ។

៦.បន្ទាប់ពីលេងល្បែងនេះសូមពន្យល់កុមារថា ថ្ងៃនេះយើងនឹងរៀនពីស្តេចគឺព្រះយេស៊ូវគ្រីស្ទនិងការស្វាគមន៍ទ្រង់។

## ៤. ការណែនាំមេរៀន

ប្រសិនបើព្រះយេស៊ូវយាងមកស្រុករបស់អ្នក តើអ្នកនឹងរៀបចំយ៉ាងណាដើម្បីទទួលទ្រង់? តើអ្នកនឹងទះដៃនៅពេលព្រះអង្គយាងចូលមកក្នុងស្រុកអ្នកឬ? តើអ្នកនឹងច្រៀងចម្រៀងឬ? តើអ្នកនឹងប្រាប់មនុស្សម្នាឲ្យមកស្វាគមន៍ និងសរសើរតម្កើងដល់ទ្រង់ឬ? ព្រះគម្ពីរប្រាប់យើងថា ថ្ងៃមួយព្រះយេស៊ូវបានយាងមកក្នុងក្រុងដោយជិះសត្វលា។ ចូរយើងបានស្វែងយល់ថា តើមនុស្សបានធ្វើអ្វីខ្លះពេលឃើញព្រះអង្គយាងមក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវយាងចូលក្រុងយេរូសាឡិមដោយជិះសត្វលា ជាផ្នែកដ៏សំខាន់នៃព័ន្ធកិច្ចរបស់ព្រះអង្គនៅលើផែនដី។ ព្រះគម្ពីរប្រាប់យើងថាប្រជាជនរំភើបចិត្តយ៉ាងជាខ្លាំង នៅថ្ងៃដែលព្រះយេស៊ូវជិះសត្វលាចូលក្រុង។នេះប្រៀបដូចជាទាហ៊ានម្នាក់ទទួលបានជ័យជម្នះ រួចធ្វើដំណើរចូលមកក្នុងទីក្រុងដោយមានមនុស្សសរសើរ និងគោរពគាត់។ មនុស្សម្នាថែមទាំងដាក់អាវរបស់ពួកគេក្រាលនៅលើផ្លូវ ខណៈអ្នកខ្លះទៀតក្រាលធាងចាកនៅលើផ្លូវ។

នៅក្នុងគម្ពីរសញ្ញាចាស់ ***សាការី ៩:៩*** បានទាយថាស្តេចនឹងចូលទៅក្នុងទីក្រុងដោយជិះលើសត្វលា។ មនុស្សសរសើរតម្កើងថា៖ “ហូសាណាថ្វាយដល់ព្រះរាជបុត្រារបស់ដាវីឌ!។” “មានពរហើយអ្នកណា ដែលមកក្នុងព្រះនាមនៃព្រះយេហូវ៉ា!” “ហូសាណានៅស្ថានសួគ៌ខ្ពស់បំផុត!” នេះជាការសរសើរពី **ទំនុកដំកើង ១១៨:២៥-២៦**។ នៅទីនោះយើងឃើញពាក្យ “ហូសាណា” ត្រូវបានបកប្រែថា “ព្រះអម្ចាស់សង្គ្រោះយើង!” ដូច្នេះយើងអាចឃើញថា មនុស្សកំពុងទទួលយក និងសរសើរព្រះយេស៊ូវថាជាព្រះអង្គសង្គ្រោះ—ព្រះមេស្ស៊ី។ ហើយព្រះយេស៊ូវមិនបានបញ្ឈប់មនុស្សទាំងអស់នោះ ពីការសរសើរទ្រង់ជាព្រះមេស្ស៊ីឡើយ ពីព្រោះទ្រង់ជាព្រះរាជបុត្រានៃព្រះដែលបានយាងមកសង្គ្រោះយើង។ តាមពិត៥ថ្ងៃក្រោយមក ព្រះយេស៊ូវត្រូវបានឆ្កាងនៅលើឈើឆ្កាង សម្រាប់អំពើបាបរបស់យើងទាំងអស់គ្នា។

ព្រះយេស៊ូវសមនឹងទទួលបាននូវការសរសើរ។ យើងត្រូវសរសើរព្រះយេស៊ូវ ពេលយើងនៅម្នាក់ឯង ឬពេលយើងនៅជាមួយអ្នកដទៃ។ ការច្រៀងសរសើរដំកើងព្រះយេស៊ូវជារឿងល្អដែលត្រូវធ្វើ។ ពេលយើងសរសើរព្រះយេស៊ូវ យើងប្រាប់ទ្រង់ថាយើងស្រឡាញ់ព្រះអង្គប៉ុណ្ណា ហើយយើងប្រាប់ព្រះអង្គថាយើងទទួលស្គាល់ថាទ្រង់ជាព្រះដ៏ល្អយ៉ាងណា។ យើងមិនចាំបាច់ចាំទាល់តែឃើញព្រះយេស៊ូវដើម្បីសរសើរទ្រង់ឡើយ។ ព្រះអង្គអាចស្តាប់អ្វីទាំងអស់ដែលយើងនិយាយ ទ្រង់ថែមទាំងដឹងពីអ្វីដែលយើងកំពុងគិត។ សូមថ្វាយការសរសើរដល់ព្រះយេស៊ូវឥឡូវនេះ។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវយាងចូលទីក្រុងណា? *ក្រុងយេរូសាឡិម*

២. តើព្រះអង្គជិះលើអ្វី? *សត្វលា*

៣.តើមនុស្សស្វាគមន៍ព្រះយេស៊ូវយ៉ាងណា?

*ដាក់អាវធំ និងធាងចាកក្រាលលើដី ហើយសរសើរដំកើងព្រះយេស៊ូវ*

៤. តើអ្នកគួរសរសើរព្រះយេស៊ូវនៅពេលណា? *គ្រប់ពេលវេលា*
៥. តើបទសរសើរមួយណាដែលអ្នកពេញចិត្ត? *ឱ្យកុមារឆ្លើយ*

## ៧. **ហត្ថកម្ម** «សរសើរតម្កើងព្រះយេស៊ូវ»



**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កូល័រទៀន កន្ត្រៃ កាវ (ឬស្កុតបិត)

១. ឱ្យក្រដាសហត្ថកម្មដែលបានបោះពុម្ពហើយទៅកុមារម្នាក់១សន្លឹកហើយឱ្យពួកគេតុបតែងវា។

២. ឲ្យពួកគេកាត់ស្លឹក និងដើមចេញ ហើយបិតវាជាប់គ្នា។

៣. ឲ្យកុមារទាំងអស់ឈរតម្រង់ជួរ ហើយស្រែកថា“ហូសាណា! មានពរហើយអ្នកណាដែលមកក្នុងព្រះនាមនៃព្រះយេហូវ៉ា!”

៤. អ្នកអាចច្រៀងចម្រៀងសរសើរដំកើងនៅពេលក្មេងៗកំពុងគ្រវីស្លឹកចាក។

## ៨. **ល្បែងកំសាន្ត** «ហ្វូងមនុស្សស្វាគមន៍ព្រះយេស៊ូវយាងមកយេរូសាឡិម»



១. ជ្រើសរើសកុមារ ១០នាក់ ឲ្យកុមារចាប់ដៃគូរពីរៗនាក់ តាមមាឌរបស់ពួកគេ

២. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារម្នាក់ត្រូវ វារ ដោយដាក់ដៃគូររបស់ពួកគេគេនៅពីលើខ្នងសំដៅទៅចុងម្ខាងនៃថ្នាក់រៀន។

៣. នៅពេលដែលពួកគេទៅដល់ចុងម្ខាងនៃថ្នាក់រៀនពួកគេត្រូវប្តូរអ្នកវារម្តងហើយត្រូវ វារ ត្រឡប់មកទីចាប់ផ្តើមវិញ។

៤. កុមារដែលមិនបានលេងអាចឈរទះដៃ នឹងស្រែកហ៊ោ ដោយគ្រវីធាងចាករបស់ពួកគេសម្រាប់អ្នកលេង ដូចដែលពួកមនុស្សបានស្រែកស្វាគមន៍សម្រាប់ព្រះយេស៊ូវដែរ។

៥. ក្រុមណាដែលអាចវាត្រឡប់មកដល់ទីបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៦. អ្នកអាចជ្រើសរើសកុមារ ១០នាក់ទៀតដើម្បីលេងប្រសិនបើមានពេលគ្រប់គ្រាន់។

៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា នៅពេលដែលព្រះបានយាងចូលក្នុងទីក្រុងយេរូសាឡិម ហើយពួកមនុស្សបានសរសើរតម្កើងទ្រង់ ដោយហៅទ្រង់ថាជាព្រះអង្គសង្គ្រោះ។

## ៩. **ខគម្ពីរចងចាំ** ទំនុកដំកើង ១១៨:២៦

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# សរសើរដំកើងព្រះយេស៊ូវ!

១.ឱក្រដាស់ហាត្ថកម្មដែលបានបោះពុម្ពហើយទៅកុមារម្នាក់ ១សន្លឹកហើយឱ្យពួកគេតុបតែងវា។
២. ឲ្យសិស្សកាត់ស្លឹក និងដើមចេញ ហើយបិតវា ជាប់គ្នា។
៣. ឲ្យក្មេងៗឈរតម្រង់ជួរ ហើយស្រែកថា "ហូសាណា! ឲ្យព្រះអង្គ ដែលយាងមកដោយនូវ ព្រះនាមព្រះយេហូវ៉ា បានប្រកបដោយព្រះពរ! "
៤. អ្នកអាចច្រៀងចម្រៀងសរសើរដំកើងនៅពេលក្មេងៗ កំពុងគ្រវីស្លឹកត្នោត។

